នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញាអន្តរជាតិ
ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2015, 14:01
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** អមដោយ ឧបសម្ព័ន្ធ**សម្ងាត់បំផុត** ពីរ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការដាក់បញ្ជាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/15**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន
**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ
**មេធាវីប្រចាំការ:**
លោកស្រី ទូច វណ្ណរ័ក្ស
លោក Calvin SAUNDERS
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

# I. ការដាក់បង្ហាញ

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ ចំនួន ២២៦ និងឯកសារពាក់ព័ន្ធនានា ដែលបានទទួលយកក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង០០២/០២ ("ឯកសារ")។ ឯកសារទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុង**ឧបសម្ព័ន្ធ ដ**។

២. សហព្រះរាជអាជ្ញា បានស្វែងរកការអនុញ្ញាតដាក់បង្ហាញឯកសារទាំងនេះ តាមរយៈសំណើចំនួនបី (រួមគ្នាហៅថា "សំណើ") ដែលបានដាក់ទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤[1], ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤[2] និងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥[3]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយល់ព្រមតាមសំណើដែលពាក់ព័ន្ធទៅនឹងឯកសារនានា ដែលបច្ចុប្បន្ននេះកំពុងត្រូវបានដាក់បង្ហាញកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥[4] ដែលសេចក្តីសម្រេចនោះត្រូវបានគេចែកជូនទៅអង្គជំនុំជម្រះសាលាដំបូងរួចហើយ។

៣. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសារពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចមួយដែលត្រូវធ្វើជូនទៅអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាជនជាប់ចោទដែរ ដោយហេតុថា "វាជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត ដែលអង្គជំនុំជម្រះមានសិទ្ធិចូលពិនិត្យមើលឯកសារទាំងនេះ"[5]។ លើសពីនេះ អង្គជំនុំជម្រះធ្លាប់បានសម្រេចពីមុនថា "វិធាន៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវឯកសារណាដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ដែលអាចជានត្តិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅ

---

[1] សំណុំរឿង០០៤-**D193** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង០០២/០២, ២ ឧសភា ២០១៤។

[2] សំណុំរឿង០០៤-**D193/7** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១, ១៥ ធ្នូ ២០១៤។

[3] សំណុំរឿង០០៤-**D193/9** សំណើរបស់ សពអ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ក្នុងសំណុំរឿង០០២/០២, ២៩ មករា ២០១៥។

[4] សំណុំរឿង០០៤-**D193/15** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសម្រាប់សំណុំរឿង០០២ - សំណើ D193, D193/7 និង D193/9, ១១ មីនា ២០១៥។

[5] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ២០១២។

លើភាពជឿជាក់បាននៃភស្តុតាង"[6]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានណែនាំថា ដំបូង សហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះ ដោយប្ដឹងពីភស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលយកឯកសារដែលបានយល់ព្រមនោះ សម្រាប់ការដាក់បង្ហាញ[7]។

៤. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានចេញសេចក្ដីបង្គាប់ពីមុនថា រាល់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ចូលទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ដោយចាត់ថ្នាក់បណ្ដោះអាសន្នជាប្រភេទឯកសារសម្ងាត់បំផុត ហើយថាអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចនៅពេលក្រោយ ថាតើគួរត្រូវប្ដូរចំណាត់ថ្នាក់ឯកសារទាំងនោះឡើងវិញជាឯកសារសម្ងាត់ដែរ ឬយ៉ាងណា[8]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា កំណត់ហេតុស្ដាប់ចម្លើយទាំងឡាយដែលមាននៅក្នុង **ឧបសម្ព័ន្ធ ង** ជាប្រភេទឯកសារសម្ងាត់បំផុត។

៥. ថ្មីៗនេះ សចអ បានធ្វើវិសោធនកម្មលើការដាក់កំហិត និងទម្រង់បែបបទដែលអនុវត្តត្រូវចំពោះឯកសារនានា ពីសំណុំរឿង០០៣ និង ០០៤ ដាក់បង្ហាញចូលទៅក្នុងសំណុំរឿង០០២[9]។ ដីកាសម្រេចនោះ បានដាក់ភ្ជាប់មកជា**ឧបសម្ព័ន្ធ ១** សម្ងាត់បំផុត។ ឥឡូវនេះ ការអនុញ្ញាតឱ្យដាក់បង្ហាញឯកសារត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវទាំងឡាយដូចតទៅ៖

ក. រាល់សម្ភារៈទាំងអស់ត្រូវចាត់ទុកថា ជាឯកសារសម្ងាត់។

ខ. ត្រូវប្ដូរសម្ភារៈទៅជាសំណៅថតចម្លងអេឡិចត្រូនិច ក្នុងទម្រង់ណាមួយដែលអាចធ្វើឱ្យអក្សរបង្កប់(watermark)ដែលមិនអាចលុបបាន នៅលើទំព័រនិមួយៗនៃឯកសារទាំងអស់ដែលកំណត់បានពីបុគ្គលិកលក្ខណៈសម្រាប់ភាគីទទួលនិមួយៗ។

---

[6] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្ដល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ២០១២, ត្រង់ទំព័រ ១។

[7] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ ២។

[8] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី"ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២", ២៤ មករា ២០១២, ត្រង់ទំព័រ ១។

[9] សំណុំរឿង០០៤- **D193/19** ដីកាសម្រេចកែប្រែដីកាសម្រេច D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15 និង D193/16 លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង០០២/០២, ១៣ មីនា ២០១៤។

គ. សម្ភារៈដែលត្រូវផ្តល់ជូនមេធាវីការពារក្តីជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ ខៀវ សំផន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិចត្រូនិចដែលមានអក្សរបង្កប់ និងកំណត់បានពីបុគ្គលិកលក្ខណៈនិមួយៗ។

ឃ. កសព ត្រូវតែបង្ហាញឯកសារក្នុងរបៀបមួយដែលភាគីនិមួយៗ អាចចូលពិនិត្យមើលបានតែតាមរយៈសំណៅថតចម្លងអេឡិចត្រូនិចដែលមានអក្សរបង្កប់ ដែលមានការកំណត់ពីបុគ្គលិកលក្ខណៈនិមួយៗរបស់ខ្លួនតែប៉ុណ្ណោះ។

ង. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញសម្ភារៈដែលបានផ្តល់ជូនតាមសេចក្តីសម្រេចនេះ ឲ្យទៅតែសមាជិកនៃក្រុមការងាររបស់ពួកគាត់ដែលទទួលបានការងារជាផ្លូវការតាមវិធាន វិធាន២២(៥) និង ១២(៤)*ស្ទួនពីរ* តែប៉ុណ្ណោះ។

ច. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កែន ឬក៏ចម្លងនូវសំណៅថតចម្លងនៃឯកសារដើម ទោះបីជាតាមរបៀបណាក៏ដោយ ដែលនាំឲ្យសមាជិកនៃក្រុមរបស់ខ្លួននិមួយៗដែលទទួលបានការណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់ យកសម្ភារៈទាំងនោះ ទៅប្រើប្រាស់ក្រៅពីការប្រើប្រាស់ផ្ទៃក្នុងរបស់ខ្លួនឡើយ។

ឆ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កែន ឬក៏ចម្លងនូវសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង គឺត្រូវរក្សាទុកក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

ជ. ក្នុងករណីដែលសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង០០២/០២ សម្ភារៈនោះត្រូវបានចាត់ទុកថាជាឯកសារសម្ងាត់។

ឈ. គ្មានសម្ភារៈណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានផ្សព្វផ្សាយដល់សាធារណជន ទោះក្នុងទម្រង់ ឬតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយក៏ដោយ។

ញ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនតាមរយៈ ដីកាសម្រេចនេះ សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការ ពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះ ជូន សចអ វិញ; និង

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះ ត្រូវរាយការណ៍អំពីការរំលោភបំពាននោះជូន សចអ។

៦. ដើម្បីអនុវត្តតាមការដាក់កម្រិតទាំងនេះ សហព្រះរាជអាជ្ញានឹងធ្វើយ៉ាងណាឲ្យសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និងមេធាវី ប្រចាំការរបស់ ខៀវ សំផន ទទួលបាននូវសម្ភារៈទាំងនេះជាសំណៅអេឡិចត្រូនិច តាមរយៈ ហ្វូលឌ័រផ្ទុកឯកសាររួម ដល់គ្រប់ភាគីទាំងអស់ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## II. **ដំណោះស្រាយដែលស្នើឡើង**

៧. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយក និងដាក់ បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ** ដ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |